រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

058KH01A-01

សេចក្តីអធិប្បាយ ដែលប្រកបដោយ ឫទ្ធានុភាពពីស្បៃរភៅដំណឹងល្អយ៉ូហាន



កូនស្បៃរភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៥៨

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នក អោយអាចបង្រៀន
ដំណឹងល្អរបស់លោកយ៉ូហានដល់ក្រុមជំនុំរបស់អ្នក ។

ដំណឹងល្អរៀបរៀង ដោយសាវ័កយ៉ូហាន

ដំណើររឿងនៅក្នុងសៀវភៅដំណឹងល្អរបស់លោកយ៉ូហាន ខុស
ប្លែកពីសៀវភៅដំណឹងល្អ ដែលសរសេរដោយលោកម៉ាថាយ
លោកម៉ាកុស និង លោកលូកា ។ គេហៅសៀវភៅដំណឹងល្អ
ម៉ាថាយ ម៉ាកុស និង លូកាថាជាសៀវភៅដំណឹងល្អ « ស៊ីណុប-
ទីក » ។ ពាក្យ « ស៊ីណុបទីក » មានន័យថា « ការរៀបរាប់អំពី
ព្រឹត្តិការណ៍ដូចគ្នា ដោយមានការយល់ឃើញប្រហាក់ប្រហែលគ្នា »
បានន័យថា អ្នកនិពន្ធទាំងនោះ បានសរសេរអំពីហេតុការណ៍
ប្រហាក់ប្រហែលគ្នា ។

រីឯលោកយ៉ូហានវិញ លោកបានសេរសេរតាមរបៀបដែលខុសពី
អ្នកនិពន្ធទាំងបីនាក់នោះ គឺ លោកសរសេរអំពីហេតុការណ៍ និង
ពត៌មានសំខាន់ៗ ដែលអ្នកនិពន្ធសៀវភៅដំណឹងល្អឯទៀតនោះ
មិនបានរៀបរាប់ ។ ក្រៅពីកត់ត្រាហេតុការណ៍សំខាន់ៗ ដែល
លោកម៉ាថាយ លោកម៉ាកុស និង លោកលូកាបានរៀបរាប់រួចមក

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនក្រុមជំនុំរបស់អ្នក អំពីដំណឹងល្អរបស់លោកយ៉ូហាន
ដោយប្រើគំរោងសេចក្តីអធិប្បាយមួយចំនួន ដែលមានជាក់
ជូននៅក្នុងសៀវភៅនេះ ។
- រៀបចំវគ្គគម្ពីរ ដែលមានការនិយាយឆ្លើយឆ្លងគ្នាច្រើន ជា
ល្ខោននិយាយ ។ ឱ្យមនុស្សផ្សេងៗគ្នាអានជាអ្នកពោល និង
តួអង្គដែលនិយាយឆ្លើយឆ្លងគ្នាក្នុងសាច់រឿង ។ បើសិនជា
វគ្គមួយវែង អ្នកពោលមិនត្រូវអានទាំងអស់ទេ តែត្រូវអាន
តែខ ដែលនាំឱ្យអាចយល់សាច់រឿងគ្រប់គ្រាន់បានហើយ ។
- អ្នកឡើងសំដែងទាំងអស់ ត្រូវអានដោយសំឡេងខ្លាំងៗ
ហើយធ្វើកាយវិការ និង ទឹកមុខ ។ នៅពេលហាត់ ពួក
គេត្រូវគូសចំណាំកន្លែងក្នុងព្រះគម្ពីរ ដែលពួកគេត្រូវអាន
រៀងៗខ្លួន ។ ត្រូវហាត់រហួតដល់ម្នាក់ៗអាចសំដែងតួរបស់
ខ្លួនបាន ដោយមិនបាច់មានគេជួយ ។ យើងសូមជូន
យោបល់ថា ត្រូវអោយមនុស្សធំសំដែង មិនត្រូវឱ្យកុមារ
សំដែងទេ ដើម្បីអោយពាក្យសំដីដែលគេអាន មានអំណាច
និង ឥទ្ធិពលខ្លាំងលើអ្នកស្តាប់ ព្រោះនេះមិនមែនជាល្ខោន
កំសាន្តទេ ។

ចំលើយ : ក- ព្រោះនាងមិនឃើញព្រះសពព្រះយេស៊ូ ។ ខ- ថានាងបានឃើញ និង និយាយជាមួយព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ ។ គ- ព្រោះខ្លាចពួកយូដា ។ ឃ- សេចក្តីសុខសាន្ត ។ ង- ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ និង ការលើកលែងទោស ។ ច- ស្នាមដែកគោលនៅលើព្រះបាទា និង ព្រះហស្តព្រះអង្គ ។ ឆ- ព្រោះយើងជឿ ទោះជាមិនបានឃើញក៏ដោយ ។ ជ- ដើម្បីអោយយើងអាចជឿ និង មានជីវិតអស់កល្ប ។

យើងស្នើសូមអោយសំដែងវគ្គនេះ អំពីព្រះយេស៊ូបង្ហាញអង្គទ្រង់អោយឃើញ ជាល្ខោននិយាយ ដោយអោយមនុស្សម្នាក់ ជាអ្នកពោលរៀបរាប់រឿង ម្នាក់ទៀតអានព្រះបន្ទូលព្រះយេស៊ូ ម្នាក់ទៀតអានជានាងម៉ារី ហើយម្នាក់ទៀតអានជាលោកថូម៉ាស ។

កំណត់ចំណាំ :

ហើយ លោកយ៉ូហានបានសរសេររៀបរាប់ជាច្រើនអំពីការសន្ទនារវាងព្រះយេស៊ូ និង សាវ័ករបស់ព្រះអង្គថែមទៀតផង ។ លោកបានកត់ត្រាទីសំគាល់ជាច្រើន ដែលបង្ហាញថា ព្រះយេស្វូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ (យ៉ូហាន ២០:៣០-៣១) ។ លោកយ៉ូហានសរសេរសៀវភៅដំណឹងល្អរបស់គាត់ ច្រើនឆ្នាំក្រោយលោកម៉ាថាយ លោកម៉ាកុស និង លោកលូកាបានសរសេរសៀវភៅដំណឹងល្អរបស់ពួកគេ ។

សាវ័កយ៉ូហានដែលសរសេរដំណឹងល្អនេះ មិនមែនជាលោកយ៉ូហានដែលធ្វើពិធីជ្រមុជទឹកថ្វាយព្រះយេស៊ូទេ ។

អត្ថបទសិក្សានេះ ផ្តល់ជូនគំរោងនៃវគ្គសំខាន់ៗរបស់ដំណឹងល្អរបស់លោកយ៉ូហាន សំរាប់បង្រៀន ។ បន្ទាប់ពីចំណុចនិមួយៗនៃគំរោងបង្រៀន នឹងមានសំណួរដែលអ្នកអាចឆ្លើយ ដោយពិនិត្យមើលវគ្គព្រះគម្ពីរ ។

សូមពិនិត្យមើលសេចក្តីសង្ខេបរបស់វគ្គគម្ពីរ យ៉ូហាន ១:១-១៨ ដែលនៅទំព័របន្ទាប់ និង ដែលមានចំណងជើងថា÷ « ព្រះយេស៊ូបង្ហាញយើងពីលក្ខណៈសម្បត្តិគ្រប់យ៉ាងរបស់ព្រះជាម្ចាស់ » ។

© Project WorldReach © SEAN

ពេលអ្នកពិនិត្យមើលគំរោងរបស់បទគម្ពីរ យ៉ូហាន ១:១-១៨ សូមកត់សំគាល់សេចក្តីខាងក្រោមនេះ :

១) ចំណុចសំខាន់ៗរបស់ដំណឹងល្អក្នុងវគ្គនេះ មានដាក់ជូនជាអក្សរធំៗ និង ចាប់ផ្តើមដោយពាក្យ «ព្រះបន្ទូលអស់កល្ប» ដែលជាប្រធានបទសំខាន់បំផុតរបស់ដំណឹងល្អក្នុងវគ្គនេះ ។ នេះជារបៀបធ្វើឱ្យចំណុចសំខាន់និមួយៗរបស់ដំណឹងល្អ នៅក្នុងវគ្គនេះ ទាក់ទងជាមួយប្រធានបទសំខាន់របស់វគ្គនេះ ។

តើគំរោងនៃយ៉ូហាន ១:១-១៨ មានចំណុច/ គោលគំនិតសំខាន់ដូចនេះប៉ុន្មាន ? ។ _____

២) ចំណុចនិមួយៗ រួមបញ្ចូលលេខយោងរបស់ព្រះគម្ពីរ (លេខជំពូក និង លេខ ខ) ដែលគេដាក់ក្នុងវង់ក្រចក ។ ខទាំងនេះទាក់ទងនឹងចំណុចពិសេសមួយរបស់គំរោង ។

តើចំណុច ទី ១ ទាក់ទងនឹងខគម្ពីរអ្វីខ្លះ ? ។

_____

ឃ) តើព្រះយេស៊ូប្រទានព្រះពរអ្វីដល់ពួកសាវក? (ខ ១៩-២១) ។

_____

ង) តើព្រះអម្ចាស់មានព្រះបន្ទូលសន្យាអ្វីដល់ពួកអ្នក ដែលជារបស់ព្រះអង្គ ? (ខ ២២-២៣) ។

_____

ព្រះយេស៊ូបង្ហាញអង្គទ្រង់អោយលោកថូម៉ាសឃើញ ។ (យ៉ូហាន ២០:២៤-៣១)

ច) តើលោកថូម៉ាសត្រូវការឃើញអ្វីសិន ទើបគាត់ជឿ ? (ខ ២៤-២៥) ។

_____

ឆ) ហេតុអ្វីបានជាយើងមានពរជាងលោកថូម៉ាស ? (ខ ២៦-២៩) ។ _____

ជ) ហេតុអ្វីបានជាលោកយ៉ូហានសរសេរអំពីការអស្ចារ្យរបស់ព្រះអម្ចាស់យេស៊ូ ? (ខ ៣០-៣១) ។

_____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ២០:១០-៣១

ប្រធានបទ : ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ បានបង្ហាញអង្គទ្រង់អោយគេឃើញ ។

ចំណុច :

ព្រះយេស៊ូគ្រីស្តបង្ហាញអង្គទ្រង់ អោយនាងម៉ារីអ្នកស្រុកម៉ាដាឡាឃើញ ។ (យ៉ូហាន ២០:១០-១៨)

ក) ហេតុអ្វីបានជានាងម៉ារីអ្នកស្រុកម៉ាដាឡាយំសោកដូច្នេះ ? (ខ ១០-១៥) ។ _____

ខ) តើនាងម៉ារីប្រាប់ពួកសាវ័កអំពីអ្វី ? (ខ ១៦-១៨) ។

_____

ព្រះយេស៊ូគ្រីស្តបង្ហាញអង្គទ្រង់ឱ្យពួកសាវ័កឃើញ ។ (យ៉ូហាន ២០:១៩-២៣)

គ) ហេតុអ្វីបានជាពួកសាវ័កបិទទ្វារបន្ទប់ចាក់សោ ? (ខ ១៩) ។

_____

ឃ) នៅពីក្រោមចំណុចនិមួយៗ មានការពន្យល់អំពីចំណុចនោះ និង លេខយោងរបស់ខគម្ពីរ ដែលទាក់ទងនឹងចំណុចទាំងនេះ ។ ការពន្យល់ (អត្ថាធិប្បាយ) មានដាក់អក្សរ « ក » « ខ » « គ » ។ល។ សំរាប់សំគាល់ ។ នៅក្នុងសៀវភៅនេះគេពន្យល់ ដោយដាក់សំនួរ ដើម្បីជួយអ្នកក្នុងការសិក្សា ។ នៅពេលដែលអ្នករៀបចំគំរោងរបស់អ្នកផ្ទាល់ សូមសរសេរការពន្យល់ជាឃ្លាធម្មតា កុំសរសេរជាសំនួរ ។

តើតួអក្សរណាមួយរបស់អក្ខរក្រម (ក ខ គ ។ល។) ដែលនៅពីមុខការពន្យល់ទីមួយ នៅក្នុងការពន្យល់ជាសំនួររបស់គំរោងយ៉ូហាន ១:១-១៨ ? ។

ចំលើយ :

១) « មានចំណុចចំនួនបី (គំរោងអាចមានចំណុចចំនួនប៉ុន្មានក៏បាន) » ។

២) « ១:១-៩ » ។

៣) « ក » ។

មុននឹងសិក្សាគំរោងបង្រៀននិមួយៗ សូមអានវគ្គគម្ពីររបស់គំរោងនិមួយៗនោះសិន ។

គំរោងអធិប្បាយអំពី យ៉ូហាន ១:១-១៨

ប្រធានបទ : ព្រះយេស៊ូបង្ហាញយើងពីលក្ខណៈសម្បត្តិគ្រប់យ៉ាង
របស់ព្រះជាម្ចាស់ ។

(ព្រះបន្ទូល = ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់)

ចំណុច :

ព្រះបន្ទូលអស់កល្បជំភ្លឺគ្រប់មនុស្ស ។ (យ៉ូហាន ១:១-៩)

ក) តើខណាមួយ ដែលនិយាយថា ព្រះបន្ទូលជាព្រះជាម្ចាស់ ? ។

_____

ខ) តើព្រះយេស៊ូបង្កើតអ្វីខ្លះ ? ។

_____

គ) តើអ្នកណាដែលមិនមែនជាពន្លឺ តែមកផ្តល់សក្ខីភាពអំពីពន្លឺ
នោះ ? ។ _____

ឃ) តើព្រះបន្ទូលប្រទានពន្លឺដល់អ្នកណា ? (ខ ៩) ។

_____

ចំលើយ : ក- «យេស៊ូអ្នកភូមិណាសារ៉ែត ជាស្តេចយូដា» ។
ខ- ពួកទាហានមិនបានហែកអាវរបស់ព្រះអង្គទេ ដើម្បីឱ្យពួកគេ
អាចចាប់ឆ្នោតអោយដឹងថា អាវនោះនឹងបានទៅលើនរណា ។
មូលហេតុរបស់ព្រះជាម្ចាស់ គឺដើម្បីបំពេញតាមសេចក្តីចែងទុកក្នុង
ព្រះគម្ពីរ ។ គ- ព្រះអង្គផ្តាំលោកយ៉ូហាន ។ ឃ- ទឹកខ្មេះ ។
ង- ព្រះអង្គមានព្រះបន្ទូលអំពីការ ដែលព្រះអង្គថ្វាយព្រះជន្ម
របស់ព្រះអង្គ ជាពលិកម្មអស់កល្បតែម្តងជាសំរេច ដើម្បីដកបាប
ចេញពីពិភពលោក ។ ច- ព្រោះព្រះអង្គសុគតទៅហើយ និង
ដើម្បីសំរេចតាមសេចក្តីចែងទុកក្នុងព្រះគម្ពីរ ។ ឆ- លោកនីកូ-
ដែម និង លោកយ៉ូសែប ជាអ្នកស្រុកអារីម៉ាថេ ។ ជ- នាងម៉ារី
ជាអ្នកស្រុកម៉ាដាឡា លោកពេត្រុស និង សាវ័កម្នាក់ទៀត ។

ច) ហេតុអ្វីបានជា ពួកទាហានមិនវាយបំបាក់ព្រះបាទារបស់ព្រះយេស៊ូ ? (ខ ៣១-៣៧) ។

_____

_____

_____

គេបញ្ចុះព្រះសពព្រះយេស៊ូ ។ (យ៉ូហាន ១៩:៣៨-៤២)

ឆ) តើមនុស្សពីរនាក់ដែលយកព្រះសពព្រះយេស៊ូ ទៅបញ្ចុះក្នុងផ្នូរ ជាអ្នកណា ? ។ _____

ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញ ។ (យ៉ូហាន ២០:១-៩)

ជ) តើអ្នកណាដែលទៅឃើញផ្នូរទទេ ? ។

_____

ព្រះបន្ទូលអស់កល្បបានក្លាយមកជាមនុស្ស ដើម្បីធ្វើអោយយើងក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ (យ៉ូហាន ១:១០-១៦)

ឯ) តើអ្នកណាដែលក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់ ? ។

_____

ឋ) នៅពេលដែលព្រះបន្ទូលគង់នៅក្នុងចំណោមមនុស្ស តើសាវ័កនឹងបានឃើញអ្វី ? (ខ ១៤) ។_____

ព្រះបន្ទូលអស់កល្បនាំអោយយើងស្គាល់ព្រះបិតា ។ (យ៉ូហាន ១:១៧-១៨)

ឍ) ព្រះជាម្ចាស់ប្រទានព្រះគម្ពីរវិន័យ តាមរយៈលោកម៉ូសេ ។ តើព្រះជាម្ចាស់សំដែងសេចក្តីពីរយ៉ាងអ្វីខ្លះ តាមរយៈព្រះ-យេស៊ូគ្រីស្ត ? ។ _____

ណ) មនុស្សយើងមិនអាចឃើញព្រះជាម្ចាស់ទេ ។ ដូច្នេះ តើយើងអាចស្គាល់ព្រះបិតា តាមរយៈអ្នកណា ? ។

_____

© Project WorldReach © SEAN

ចំលើយ : ក- ខ ទីមួយ ។ ខ- អ្វីៗសព្វសារពើ ។ គ- លោកយ៉ូហានដែលធ្វើពិធីជ្រមុជទឹក ។ ឃ- មនុស្សគ្រប់រូប ។ ង- អស់អ្នកដែលបានជឿព្រះយេស៊ូគ្រីស្ត ។ ច- សិរីរុងរឿងរបស់ព្រះបុត្រា ។ ឆ- ព្រះហឫទ័យប្រណីសន្តោស និង សេចក្តីពិត ។ ជ- ព្រះយេស៊ូគ្រីស្ត ។



ខ) ពួកទាហាននាំគ្នាចាប់ឆ្មោតយកអាវព្រះយេស៊ូ ដោយសារមូលហេតុពីរយ៉ាង គឺអ្វីខ្លះ ? (ខ ២៣-២៤) ។

មូលហេតុរបស់ពួកទាហាន គឺ :

_____

មូលហេតុរបស់ព្រះជាម្ចាស់ គឺ :

_____

គ) តើព្រះយេស៊ូផ្តាំអ្នកណា អោយថែរក្សាមាតារបស់ព្រះអង្គ ? (១៩:២៥-២៧) ។ _____

ព្រះយេស៊ូគ្រីស្តថ្វាយជីវិតព្រះអង្គ ដើម្បីយើង ។ (យ៉ូហាន ១៩: ២៨-៣៧)

ឃ) តើពួកទាហានថ្វាយអ្វីឱ្យព្រះយេស៊ូសោយ នៅពេលដែលព្រះអង្គស្រេកទឹក នៅលើឈើឆ្កាង ? (ខ ២៨-២៩) ។

_____

ង) ហេតុអ្វីបានជាព្រះយេស៊ូមានព្រះបន្ទូលថា÷ «ខ្ញុំបានសំរេចសព្វគ្រប់អស់ហើយ » ? (ខ ៣០) ។

_____

© Project WorldReach © SEAN

ដែលមានប្រសាសន៍ថាខ្ញុំជាស្តេច ។ ខ្ញុំកើតមកហើយ ខ្ញុំមកក្នុងលោកនេះ ដើម្បីផ្តល់សក្ខីភាពអំពីការពិត...» ។ ឆ- ដើម្បីផ្តល់សក្ខីភាពអំពីការពិត ។ ជ- គ្មានឆ្លើយអ្វីទេ ។ ឈ- ព្រោះគាត់មិនមែននៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចនេះ គាត់មិនយល់ពីសេចក្តីខាងព្រលឹងវិញ្ញាណទេ ។ ញ- ពីព្រោះព្រះយេស៊ូអះអាងថា ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ ។ ដ- គ្មានទេ ។ ឋ- «ប្រសិនបើមិនបានទទួលអំណាចពីស្ថានលើ លោកគ្មានអំណាចលើខ្ញុំឡើយ » ។ ឌ- ព្រះបិតា ។

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ១៩:១៧-៤២ និង យ៉ូហាន ២០:១-៩

ប្រធានបទ : ព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ដំណឹងល្អ ។

ចំណុច :

ព្រះយេស៊ូគ្រីស្តត្រូវគេឆ្កាងលើឈើឆ្កាង ។ (យ៉ូហាន ១៩:១៧-២៧)

ក) តើលោកពីឡាត់អោយគេសរសេរពាក្យអ្វីបោះភ្ជាប់លើឈើឆ្កាង ? (ខ ១៧-២២) ។

_____

គំរោងអធិប្បាយអំពីយ៉ូហាន ១:១៩-៣៤

ប្រធានបទ : សូមនិយាយប្រាប់មិត្តភក្តិយើងអំពីព្រះយេស៊ូ តាមរបៀបដែលលោកយ៉ូហាន ដែលធ្វើពិធីជ្រមុជទឹកបានធ្វើ ។

ចំណុច :

លោកយ៉ូហានដែលធ្វើពិធីជ្រមុជទឹក នាំមនុស្សឱ្យចាប់អារម្មណ៍លើព្រះគ្រីស្ត មិនមែនលើគាត់ទេ ។ (យ៉ូហាន ១:១៩-២៨)

ក) មនុស្សជាច្រើនបានទៅទន្លេយ័រដាន់ ។ ពួកគេកែប្រែចិត្តគំនិតចេញពីអំពើបាប ហើយទទួលពិធីជ្រមុជទឹក ។ ពួកផារីស៊ីបានសួរលោកយ៉ូហានថា លោកជាអ្នកណា ។ ពួកផារីស៊ីខ្លះថា លោកយ៉ូហានជាព្រះគ្រីស្ត ឬ ជាព្យាការីអេលី ។ លោកយ៉ូហានឆ្លើយប្រាប់ថា លោកគ្រាន់តែជា _____ ។

«ព្រះគ្រីស្ត » (ដែលជាភាសាហេប្រឺថា÷ «ព្រះមេស្ស៊ី ») មានន័យថាព្រះមហាក្សត្រ ដែលព្រះជាម្ចាស់ប្រទានឫទ្ធានុភាព ចាត់តាំងឱ្យរំដោះប្រជារាស្ត្ររបស់ព្រះអង្គ ។ ប្រទានឫទ្ធានុភាព បានន័យថា ចាក់ប្រេងតាំងលើ ទុកជានិមិត្តរូបអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ។

ខ) តើលោកយ៉ូហានបានទទួលស្គាល់ថា លោកមិនសមនឹងកិច្ចការអ្វីខ្លះ ? ។_____

_____

លោកយ៉ូហានជាអ្នកធ្វើពិធីជ្រមុជទឹក ប្រកាសថា ព្រះយេស៊ូដកបាបចេញពីមនុស្សលោក ។ (យ៉ូហាន ១:២៩-៣១)

គ) នៅក្នុងសម្ពន្ធមេត្រីចាស់ មនុស្សមានបាបយកកូនចៀមទៅថ្វាយជាយញ្ញបូជា ដើម្បីអោយព្រះជាម្ចាស់លើកលែងទោស គឺថា «ព្រះអង្គបានដកបាបយើងចេញ » ។ តើលោកយ៉ូហានប្រៀបធៀបព្រះយេស៊ូទៅនឹងសត្វអ្វី ? ។

_____

ឃ) ហេតុអ្វីបានជាលោកយ៉ូហានហៅព្រះយេស៊ូថា ជា «កូនចៀម » ? ។

_____

_____

_____

ម្តេចក៏អ្នកមិនឱយមកខ្ញុំដូច្នេះ ? អ្នកមិនដឹងថាខ្ញុំមានអំណាចដោះលែងអ្នកក៏បាន ឬ ឆ្កាងអ្នកក៏បានទេឬ ? (យ៉ូហាន ១៩:១០)

ច) តើព្រះយេស៊ូឆ្លើយដូចម្តេច ? (១៩:១១) ។

_____

_____

_____

ឆ) តើអ្នកណាប្រទានអំណាចអោយលោកពីឡាត់ អនុញ្ញាតិឱ្យគេធ្វើគុតព្រះយេស៊ូ ? (១៩:១១) ។

_____

ចំលើយ : ក- ពីព្រោះច្បាប់រ៉ូម៉ាំង មិនអនុញ្ញាតិអោយជនជាតិយូដាប្រហារជីវិតអ្នកណាសោះឡើយ ។ ខ- «លោកមានប្រសាសន៍ដូច្នេះ តើមកពីគំនិតផ្ទាល់របស់លោក ឬមានអ្នកផ្សេងទៀតជំរាបលោក ?» ។ គ- ជនជាតិយូដាជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយព្រះយេស៊ូក៏ជាព្រះអម្ចាស់ និង ជាស្តេចខាងព្រលឹងវិញ្ញាណរបស់ពួកគេដែរ ។ ឃ- «រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ...» ។ ង- គ្មានទេ ។ ច- «លោកទេតើ

អ្វីទៅជាសេចក្តីពិតនោះ ? (យ៉ូហាន ១៨:៣៨)

ជ) តើព្រះយេស៊ូឆ្លើយដែរឬទេ ? ។ _____

ឈ) ហេតុអ្វីបានជាអ្នកដឹកនាំរដ្ឋអំណាច ដែលមិនមែនជាគ្រីស្ត-ជន ដូចលោកពីឡាត់ មិនត្រូវវិនិច្ឆ័យរឿងហេតុដែលកើតមានក្នុងក្រុមជំនុំ ? ។

_____

អ្នកមកពីណា ? (យ៉ូហាន ១៩:៩)

ញ) ហេតុអ្វីបានជាលោកពីឡាត់ភ័យខ្លាច ? (១៩:៧-៨) ។

_____

_____

_____

ដ) តើព្រះយេស៊ូតបតទៅគេវិញដែរឬទេ ? (ប្រៀបធៀបនឹងបទគម្ពីរ អេសាយ ៥៣:៧) ។_____

លោកយ៉ូហានប្រកាសថា ព្រះយេស៊ូនឹងធ្វើពិធីជ្រមុជឱ្យយើងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ។ (យ៉ូហាន ១:៣២-៣៤)

ឯ) លោកយ៉ូហានធ្វើពិធីជ្រមុជទឹកអោយមនុស្សក្នុងទឹក ។ តើព្រះយេស៊ូនឹងជ្រមុជអ្នកជឿ យ៉ាងដូចម្តេច ? ។

_____

ឋ) តើអ្នកដឹងថា មានវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងចិត្តអ្នក ដូចលោកយ៉ូហានបានទាយទុកឬទេ ? ។ _____

ឌ) ពួកសាវ័កដំបូងរបស់ព្រះយេស៊ូ បានដើរតាមលោកយ៉ូហានបាទីស្តមុននឹងជួបព្រះយេស៊ូ ។ តែដោយសារបានឮពីទីបន្ទាល់របស់លោកយ៉ូហាន ពួកគេក៏ដើរតាមព្រះយេស៊ូវិញ ។ តើអ្នកចង់ឱ្យហ្វូងចៀមរបស់អ្នកដើរតាមអ្នក ឬដើរតាមព្រះយេស៊ូ ? ។_____

ចំលើយ : ក- សំឡេងបុរសម្នាក់ ដែលស្រែកក្នុងវាលរហោ-ស្ថាន ។ ខ- ស្រាយខ្សែស្បែកជើង និង ឋានៈរបស់ព្រះយេស៊ូ ។ គ- កូនចៀម ។ ឃ- ពីព្រោះព្រះអង្គដកបាបចេញពីមនុស្សលោក ។ ង- ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ច- ចំលើយរបស់ខ្លួនអ្នកផ្ទាល់ ។ ឆ- ចំលើយរបស់ខ្លួនអ្នកផ្ទាល់ ។

គំរោងអធិប្បាយអំពី យ៉ូហាន ២:១-១២

ប្រធានបទ : តើការអស្ចារ្យទីមួយរបស់ព្រះយេស៊ូបង្ហាញអំពីអ្វី ? ។

ចំណុច :

ការអស្ចារ្យទីមួយរបស់ព្រះយេស៊ូបង្ហាញថា ព្រះអង្គរួមចំណែកជាមួយយើងក្នុងការរស់នៅប្រចាំថ្ងៃ និង អំណរសប្បាយរបស់យើង ។ (យ៉ូហាន ២:១-២)

ក) ព្រះយេស៊ូបានយាងទៅចូលរួមពិធីមង្គលការមួយ ជាមួយពួកសិស្សរបស់ព្រះអង្គ ហើយបានធ្វើឱ្យទឹកក្លាយជាស្រាទំពាំងបាយជូរ ។ នៅក្នុងព្រះគម្ពីរ ពិធីមង្គលការជាឱកាសសប្បាយរីករាយ ។ ស្រាទំពាំងបាយជូរជានិមិត្តរូបអំពីព្រះ-ពររបស់ព្រះជាម្ចាស់ ។ បច្ចុប្បន្ននេះ កូនក្រមុំ និង កូនកំលោះក៏ត្រូវយាងព្រះយេស៊ូ មកចូលរួមក្នុងពិធីមង្គលការរបស់ខ្លួនដែរ ។ បើពួកគេធ្វើដូចនេះ គឺពួកគេយាងទ្រង់ឱ្យចូលរួមចំណែកក្នុងក្រុមគ្រួសារ និង ជីវិតរបស់ពួកគេ គឺធ្វើជាសិរសា /ម្ចាស់លើជីវិតរបស់ពួកគេ ។ ហេតុអ្វីបានជាត្រូវទូលសូមឱ្យព្រះជាម្ចាស់ប្រទានពរឱ្យជីវិតអាពាហ៍ពិពាហ៍ ? ។

_____

គ) តើព្រះយេស៊ូជាស្តេចដូចម្តេចរបស់ជនជាតិយូដា ? ។

_____

_____

តើអ្នកបានធ្វើអ្វី ? (យ៉ូហាន ១៨:៣៥)

ឃ) តើព្រះយេស៊ូឆ្លើយដូចម្តេច ? (ខ ៣៦) ។ _____

_____

_____

ង) តើព្រះយេស៊ូបានធ្វើអ្វីខុស ? ។ _____

បើដូច្នេះ តើអ្នកជាស្តេចមែនឬ ? (យ៉ូហាន ១៨:៣៧)

ច) តើព្រះយេស៊ូឆ្លើយដូចម្តេច ? (ខ ៣៧) ។

_____

_____

_____

ឆ) តើព្រះយេស៊ូមានព្រះបន្ទូលថា ព្រះអង្គយាងមកក្នុងលោកនេះ ដើម្បីធ្វើអ្វី ? ។

_____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី
យ៉ូហាន ១៨:២៨ ដល់ ១៩:១៦

ប្រធានបទ : សំណួររបស់លោកពីឡាត់ ។

(យើងស្នើសូមអោយមនុស្សម្នាក់អានពាក្យសំដីរបស់លោកពីឡាត់ ម្នាក់ទៀតអានចំលើយរបស់ព្រះយេស៊ូ ជាល្ខោននិយាយមួយ ។ សូមហាត់អានជាមុនសិន) ។

ចំណុច :

តើអ្នកជាស្តេចរបស់ជនជាតិយូដាមែនឬ ? (យ៉ូហាន ១៨:៣៣)

ក) អានហេតុការណ៍ដែលបានកើតមុននេះ ក្នុងយ៉ូហាន ១៨: ២៨-៣២ ។ ហេតុអ្វីបានជាជនជាតិយូដា ចង់ឱ្យលោក ពីឡាត់វិនិច្ឆ័យទោសព្រះយេស៊ូ ? ។

_____

_____

ខ) តើព្រះយេស៊ូឆ្លើយដូចម្តេចខ្លះ ចំពោះសំណួររបស់លោក ពីឡាត់ ? (ខ ៣៣-៣៤) ។ _____

_____

ខ) តើពិធីមង្គលការត្រូវគេប្រារព្ធធ្វើនៅឯណា ? ។

_____

គ) តើដំណឹងល្អនាំអោយមានអំណរ ក្នុងជីវិតប្រចាំថ្ងៃដែរឬទេ ? ។

_____

ការអស្ចារ្យទីមួយរបស់ព្រះយេស៊ូ បង្ហាញពីព្រះហឫទ័យមេត្តា-ករុណាដល់មនុស្សដែលមានការខ្វះខាត ។ (យ៉ូហាន ២:៣-១០)

ឃ) តើគេខ្វះអ្វី នៅពេលនោះ ? ។_____

ង) មាតារបស់ព្រះអង្គប្រាប់មនុស្សអោយទៅទូលសូមព្រះយេស៊ូ ដោយផ្ទាល់ ។ សព្វថ្ងៃនេះ តើយើងត្រូវយកសេចក្តីត្រូវការ របស់យើងទៅថ្វាយអ្នកណា ? ។ _____

ច) នៅក្នុងសម្ពន្ធមេត្រីចាស់ លោកម៉ូសេធ្វើអោយទឹកក្លាយជា ឈាម ដែលជាគ្រោះអាសន្ន ។ ការអស្ចារ្យទីមួយរបស់ ព្រះយេស៊ូនៅក្នុងសម្ពន្ធមេត្រីថ្មីជាព្រះពរ ។ តើព្រះអង្គធ្វើ អោយទឹកក្លាយជាអ្វី ? ។_____

ឆ) តើអ្នកមើលឃើញថា សេចក្តីត្រូវការអ្វីខ្លះ នៅក្នុងគ្រួសារ
របស់អ្នក ក្រុមជំនុំរបស់អ្នក ឬ សហគមន៍របស់អ្នក ដែល
អ្នកត្រូវទូលសូមព្រះយេស៊ូអោយបំពេញ ? ។

_____

_____

_____

_____

_____

_____

**ការអស្ចារ្យទីមួយរបស់ព្រះយេស៊ូ បានបង្ហាញពីសិរីរុងរឿងរបស់
ព្រះអង្គ ។ (យ៉ូហាន ២:១១-១២)**

ជ) ពេលដែលព្រះយេស៊ូធ្វើការអស្ចារ្យនេះហើយ តើពួកសិស្ស
ព្រះអង្គធ្វើដូចម្តេច ? ។

_____

ឌ) តើព្រះយេស៊ូទូលសូមអោយបានស្ថិតនៅក្នុងអ្នកណា ?
(ខ ២៦) ។ _____

ចំលើយ : ក- គឺជាពេលដែលព្រះយេស៊ូត្រូវគេឆ្កាង ។ ខ-
ដើម្បីផ្តល់ជីវិតអស់កល្បដល់ពួកអ្នកដែលព្រះបិតាបានប្រទានដល់
ព្រះអង្គ ។ គ- ជាការស្គាល់ព្រះជាម្ចាស់ពិត ។ ឃ- តាំង
ពីមុនកំណើតពិភពលោក ។ ង- ព្រះបិតា ។ ច- ថាព្រះបិតា
បានចាត់ព្រះយេស៊ូឱ្យមក ។ ឆ- ដើម្បីអោយយើងរួមគ្នាជាអង្គតែ
មួយ ។ ជ- ពីអំណាចមារកំណាច ។ ឈ- អត់ទេ ។ ញ-
យើងត្រូវរួមគ្នាជាអង្គតែមួយក្នុងព្រះជាម្ចាស់ ដូចព្រះយេស៊ូស្ថិត
នៅជាប់នឹងព្រះបិតា ហើយព្រះបិតាស្ថិតនៅជាប់នឹងព្រះអង្គ ។
ដ- ចំលើយផ្ទាល់ខ្លួន ។ ថ- សិរីរុងរឿងរបស់ព្រះយេស៊ូ ពេល
ព្រះអង្គគង់នៅជាមួយព្រះបិតា ។ ឌ- ក្នុងយើង ។

© Project WorldReach © SEAN

ព្រះអម្ចាស់យេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ ធ្វើអោយយើងបានរួមគ្នា ។ (យ៉ូហាន ១៧:២០-២៣)

ញ) តើយើងជាអ្នកជឿត្រូវរួមគ្នាតែមួយ ដូចនរណា និង នរណាដែលរួមគ្នាតែមួយអស់កល្បជានិច្ចនោះ ? (ខ ២០-២១) ។

_____

_____

ដ) តើយើងអាចធ្វើដូចម្តេច ដើម្បីអោយកាន់តែមានឯកភាពខ្លាំងឡើង ក្នុងចំណោមសាវ័ករបស់ព្រះយេស៊ូ ? ។

_____

_____

ព្រះអម្ចាស់យេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ សំដែងសិរីរុងរឿងរបស់ព្រះអង្គ អោយយើងរាល់គ្នាឃើញ ។ (យ៉ូហាន ១៧:២៤-២៦)

ឋ) តើព្រះយេស៊ូទូលសូមអោយយើងបានឃើញអ្វី ? (ខ ២៤) ។

_____

_____

ឍ) តើយើងត្រូវធ្វើដូចម្តេច ដើម្បីអោយអាចឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់ សព្វថ្ងៃនេះ ? ។

_____

_____

ចំលើយ : ក- ដើម្បីទូលសូមឱ្យព្រះគ្រីស្តធ្វើជាសិរសា , ម្ចាស់លើក្រុមគ្រួសារ និង ជីវិតរបស់ពួកគេ ។ ខ- នៅភូមិកាណាក្នុងស្រុកកាលីឡេ ។ គ- នាំឱ្យមានអំណរ ។ ឃ- ខ្វះស្រាទំពាំងបាយជូរ ។ ង- ព្រះយេស៊ូគ្រីស្ត ។ ច- ស្រាទំពាំងបាយជូរ ។ ឆ- ចំលើយផ្ទាល់ខ្លួន ។ ជ- ពួកគេជឿលើព្រះអង្គ ។ ឈ- បើសិនជាយើងបែរមករកព្រះអង្គ អធិស្ឋានទូលសូមអោយព្រះអង្គប្រទានអ្វីៗដែលយើង និង មនុស្សឯទៀតត្រូវការ ដើម្បីប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ដូចពួកអ្នកបំរើនៅក្នុងពិធីមង្គលការនោះ យើងនឹងឃើញសិរីរុងរឿង និង ឫទ្ធានុភាពរបស់ព្រះអង្គដោយសារសេចក្តីអធិស្ឋានរបស់យើងជាមិនខាន ។

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ២:១៣-២២

ប្រធានបទ : របៀបកែតម្រូវកំហុសនៅក្នុងក្រុមជំនុំ ។

ចំណុច :

យើងកែតម្រូវកំហុសជាក់ស្តែង ដែលមានភស្តុតាង (មិនមែនដោយសារឮពាក្យចចាមអារាមទេ) ។ (យ៉ូហាន ២:១៣-១៤)

ក) តើព្រះយេស៊ូ និង ពួកសាវ័កនៅឯណា ? ។

_____

ខ) ព្រះយេស៊ូមិនធ្វើសកម្មភាពតាមពាក្យចចាមអារាម ឬ ពាក្យនិយាយដើមគ្នាទេ តែតាមការដែលព្រះអង្គសង្កេតមើលមនុស្សផ្ទាល់ ។ តើព្រះអង្គមើលឃើញកំហុសអ្វីខ្លះ នៅក្នុងព្រះវិហារ ? ។

_____

_____

_____

_____

ឃ) តើព្រះបិតាប្រទានឱ្យព្រះយេស៊ូមានសិរីរុងរឿងរបស់ព្រះអង្គនៅពេលណា ? (ខ ៥) ។ _____

ង) តើអ្នកណាប្រទានសាវ័កថ្វាយព្រះយេស៊ូ ? (ខ ៦) ។

_____

ច) តើពួកសាវ័ករបស់ព្រះយេស៊ូជឿថាដូចម្តេច ? (ខ ៧-៨) ។

_____

ព្រះអម្ចាស់យេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ ថែរក្សាយើងរាល់គ្នា ។ (យ៉ូហាន ១៧:១១-១៥)

ឆ) ហេតុអ្វីបានជាព្រះយេស៊ូ ទូលសូមអោយព្រះបិតាព្រះអង្គថែរក្សាយើង ? (ខ ១១) ។

_____

ជ) តើព្រះយេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ ការពារយើងពីអ្វី ? (ខ ១៥) ។

_____

ឈ) តើព្រះយេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ យកយើងចេញពីលោកនេះដែរឬទេ ? ។ _____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ជំពូក ១៧

ប្រធានបទ : ព្រះយេស៊ូគ្រីស្តអធិស្ឋានសំរាប់ពួកអ្នក ដែលជារបស់ព្រះអង្គ ។

ចំណុច :

ព្រះយេស៊ូទូលសូមអោយព្រះបិតាព្រះអង្គ ប្រទានអោយយើងមានជីវិតអស់កល្ប ។ (យ៉ូហាន ១៧:១-១០)

ក) ព្រះយេស៊ូអធិស្ឋាននៅថ្ងៃព្រហស្បតិ៍ នៅពិធីជប់លៀងចុងក្រោយបង្អស់ មុនដែលគេចាប់ព្រះអង្គនៅក្នុងសួនកេត-សេម៉ានី ។ នោះព្រះអង្គមានព្រះបន្ទូលថា « ដល់ពេលកំណត់ហើយ » តើពាក្យនេះមានន័យដូចម្តេច ? (ខ ១) ។

_____

ខ) ហេតុអ្វីបានជាព្រះបិតាប្រទានអំណាចថ្វាយព្រះយេស៊ូ ? (ខ ២) ។

_____

_____

គ) តើជីវិតអស់កល្បជាអ្វី ? (ខ ៣) ។ _____

_____

យើងកែតម្រូវកំហុសជាក់ស្តែងដោយក្លាហាន និង ដោយចិត្តស្លូតបូត ។ (យ៉ូហាន ២:១៥-១៧)

គ) តើព្រះយេស៊ូធ្វើដូចម្តេចជាមួយពួកអ្នក ដែលប្រើសាសនាសំរាប់កេងយកផលប្រយោជន៍ ? ។

_____

ឃ) ត្រូវកែតម្រូវកំហុសដោយទឹកចិត្តស្លូតបូត ពីព្រោះយើងក៏ជាមនុស្សមានបាបដែរ (ម៉ាថាយ ៧:១, កាឡាទី ៦:១) ។ ព្រមនឹងនេះ យើងកែតម្រូវពួកគេដោយក្លាហាន និង ដោយម៉ឺងម៉ាត់ ហើយនិយាយដោយផ្ទាល់ជាមួយអ្នក ដែលធ្វើខុស ។ យើងមិនត្រូវទិតៀនពួកគេប្រាប់គេឯងគ្រប់គ្នាទេ ។ ព្រោះអ្វី ? ។

_____

_____

_____

_____

_____

យើងកែតម្រូវកំហុស ដោយអំណាចរបស់ព្រះយេស៊ូគ្រីស្ត (មិនមែនដោយអំណាចរបស់យើងផ្ទាល់ទេ) ។ (យ៉ូហាន ២:១៨-២២)

ង) ពួកយូដាទូលសួរថា ព្រះអម្ចាស់មានទីសំគាល់អ្វីសំរាប់បញ្ជាក់ពីអំណាចរបស់ព្រះអង្គ ។ ព្រះយេស៊ូមានអំណាចមកពីព្រះបិតារបស់ព្រះអង្គ ។ យើងក៏មានអំណាចនោះដែរ នៅពេលដែលយើងធ្វើសកម្មភាព ស្របតាមព្រះហឫទ័យរបស់ព្រះគ្រីស្ត និង ក្នុងព្រះនាមព្រះអង្គ ។ តើព្រះយេស៊ូមានព្រះបន្ទូលពីព្រះវិហារណាមួយ ? ។

_____

ច) តើអ្នកមើលឃើញកំហុសណាមួយក្នុងក្រុមជំនុំ ដែលអ្នកអាចកែតម្រូវដោយចិត្តក្លាហាន និង ស្លូតបូត ? ។

_____

_____

_____

_____

ព្រះដ៏ជួយការពារ ថ្វាយសិរីរុងរឿងទៅព្រះយេស៊ូគ្រីស្ត ។ (យ៉ូហាន ១៦:១២-១៥)

ឃ) បើតាម ខ ១៤ តើព្រះវិញ្ញាណដ៏វិសុទ្ធថ្វាយសិរីរុងរឿងទៅអ្នកណា ? ។_____

ង) បើសិនជាគ្មានព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំទេ តើយើងអាចដើរតាមព្រះយេស៊ូគ្រីស្តដែរឬទេ ? ។_____

ចំលើយ : ក- ដើម្បីអាចប្រទានព្រះវិញ្ញាណព្រះអង្គឱ្យយាងមក (គង់នៅជាមួយយើងរាល់គ្នា) ។ ខ- ព្រះបុត្រា គឺព្រះយេស៊ូ ។ គ- អំពើបាប សេចក្តីសុចរិត និង ការកាត់ទោស ។ ឃ- ព្រះយេស៊ូ ។ ង- មិនអាចទេ ។



គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ១៦:៥-១៥

ប្រធានបទ : កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

ចំណុច :

ព្រះយេស៊ូប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះដ៏ជួយការពារ អោយយាងមកគង់ជាមួយយើង ។ (យ៉ូហាន ១៦:៥-៧)

ក) ហេតុអ្វីបានជាព្រះយេស៊ូត្រូវយាងចេញពីពិភពលោកនេះ ទាំងព្រះកាយ ? (ខ ៧) ។ _____

ខ) តើអ្នកណាចាត់ព្រះដ៏ជួយការពារឱ្យយាងមករកយើង ? (ខ ៧) ។ _____

ព្រះដ៏ជួយការពារ បើកសំដែងអោយមនុស្សយល់ដឹងសេចក្តីពិត ។ (យ៉ូហាន ១៦:៨-១១)

គ) តើសេចក្តីទាំងបីយ៉ាង ដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ បើកសំដែងអោយមនុស្សយល់ត្រឹមត្រូវ គឺអ្វីខ្លះ ? (ខ ៨) ។

_____

_____

ចំលើយ : ក- ក្រុងយេរូសាឡឹម ។ ខ- អ្នកលក់សត្វ (សំរាប់ថ្វាយជាយញ្ញបូជា) និង អ្នកប្តូរប្រាក់ ។ គ- ព្រះអង្គយកខ្សែធ្វើរំពាត់ ដេញអ្នកទាំងនោះចេញពីព្រះវិហារ ។ ឃ- ព្រះយេស៊ូបង្រៀនយើងមិនឱ្យវិនិច្ឆ័យ ឬ ដាក់ទោស (ម៉ាថាយ ៧:១) ។ ង- ព្រះកាយព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញ ។ ច- ចំលើយផ្ទាល់ខ្លួន ។



គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ៣:១-១៥

ប្រធានបទ : ទោះជាមនុស្សប្រកាន់សាសនាខ្ជាប់ខ្ជួនយ៉ាងណា ក៏ចាំបាច់ត្រូវកើតជាថ្មីដែរ ។

ចំណុច :

លោកនីកូដែមស្វែងរកព្រះយេស៊ូ ។ (យ៉ូហាន ៣:១-២)

ក) តើលោកនីកូដែម នៅក្នុងគណៈសាសនាណា ? ។

_____

ខ) តើលោកនីកូដែមមកជួបព្រះយេស៊ូពេលណា ? ។

_____

លោកនីកូដែមដឹងថា គាត់មានការខ្វះខាតខាងព្រលឹងវិញ្ញាណ ។ (យ៉ូហាន ៣:៣-៨)

គ) ដំបូងយើងកើតពីទឹក / សាច់ឈាម ហើយយើងត្រូវកើតជាលើកទីពីរដោយសារអ្វី ? ។ _____

ឈ) តើ « សេចក្តីបង្គាប់ថ្មី » ដែលព្រះយេស៊ូប្រទានអោយយើងណាមួយ ដែលសំខាន់បំផុតនោះ ? (យ៉ូហាន ១៣:៣៤) ។

_____

សូមសរសេរសេចក្តីសំខាន់ជាងគេនៅក្នុង ខ ២១ ធ្វើជាចំណុចទីបី :

_____

_____

តើយ៉ូហាន ១៤:១៤-២១ បង្រៀនយើងឱ្យធ្វើកិច្ចការអ្វី ? ។

_____

_____

ចំលើយ : ក- ជារៀងរហូត ។ ខ- ព្រះវិញ្ញាណនៃសេចក្តីពិត (ព្រះវិញ្ញាណដ៏វិសុទ្ធ) ។ គ- ព្រះយេស៊ូក៏យាងមកដែរ ។ ឃ- ពួកសាវ័កអាចឃើញព្រះអង្គ ។ ង- មនុស្សលោកទាំងអស់មិនបានឃើញព្រះអង្គទេ ។ ច- ក្នុងព្រះយេស៊ូ ។ ឆ- ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។ ជ- ព្រះយេស៊ូ និង ព្រះបិតាព្រះអង្គ ។ ឈ- យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក ។

(យ៉ូហាន ១៤:១៩-២០)

ឃ) ក្រោយពេលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ តើពួកសាវ័កអាចឃើញព្រះអង្គដែរឬទេ ? (ខ ១៩) ។ _____

ង) តើមនុស្សទាំងអស់អាចឃើញព្រះអង្គដែរឬទេ ? (ខ ១៩) ។

_____

ច) ព្រះយេស៊ូនៅក្នុងព្រះបិតា ហើយនៅក្នុងយើងរាល់គ្នាដែរ ។ តើយើងនៅក្នុងអ្នកណា ? (ខ ២០) ។ _____

សូមសរសេរសេចក្តីដែលសំខាន់ជាងគេនៅក្នុង ខ ១៩-២០ ធ្វើជាចំណុចទីពីរ :

_____

_____

(យ៉ូហាន ១៤:២១)

ឆ) តើអ្នកដែលស្រឡាញ់ព្រះយេស៊ូ ត្រូវធ្វើដូចម្តេច ? ។

_____

ជ) តើអ្នកណាដែលនឹងស្រឡាញ់អ្នក ដែលប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ ? ។_____

លោកនីកូដែមជឿលើព្រះយេស៊ូ ។ (យ៉ូហាន ៣:៩-១៦ និង យ៉ូហាន ១៩:៣៩-៤២)

ឃ) តើយើងត្រូវធ្វើដូចម្តេច ដើម្បីអោយបានកើតពីព្រះវិញ្ញាណដ៏វិសុទ្ធ (យ៉ូហាន ៣:៩-១៦) ? ។

_____

ង) តើក្រោយមក លោកនីកូដែមបានធ្វើអ្វី ដែលបង្ហាញថាលោកជឿលើព្រះយេស៊ូ (យ៉ូហាន ១៩:៣៩-៤២) ? ។

_____

ច) បើសិនជាជំនឿរបស់យើងមិនមានផលផ្លែជាការប្រព្រឹត្តល្អទេ តើជំនឿរបស់យើងនេះ ជាជំនឿប្រភេទណា (យ៉ាកុប ២:១៧) ? ។

_____

ចំលើយ : ក- គណៈផារីស៊ី ។ ខ- ពេលយប់ ។ គ- ព្រះ-វិញ្ញាណ ។ ឃ- ជឿលើព្រះយេស៊ូគ្រីស្ត ។ ង- ជួយរៀបចំព្រះសពព្រះយេស៊ូដើម្បីបញ្ចុះ ។ ច- ជំនឿស្លាប់ (ដែលមិនសង្គ្រោះ) ។

© Project WorldReach © SEAN

យើងស្នើសូមអោយអ្នកសំដែងរឿងព្រះគម្ពីរនេះ ជាឆាកល្ខោនខ្លី មួយ (មនុស្សម្នាក់អានពាក្យសំដីរបស់លោកនីកូដែម ម្នាក់ទៀត អានព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយ «អ្នកពោល» អានសេចក្តីផ្សេងៗក្នុងវគ្គ ដើម្បីពន្យល់បរិបទ) ។



គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ១៤:១៥-២១

សរសេរប្រធានបទរបស់វគ្គនេះទាំងមូល ។

ប្រធានបទ : _____

_____

ចំណុច :

(យ៉ូហាន ១៤:១៥-១៨)

ក) តើ «ព្រះដ៏ជួយការពារមួយអង្គទៀត» ដែលព្រះយេស៊ូសន្យាដល់សាវ័កស្មោះត្រង់ នឹងគង់នៅជាមួយយើងរហូតដល់ណា ? (ខ ១៥-១៦) ។ _____

ខ) តើព្រះដ៏ជួយការពារនោះជានរណា ? (១៦-១៧) ។

_____

គ) តើព្រះយេស៊ូនឹងយាងមករកយើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធដែរឬទេ ? (ខ ១៨) ។ _____

សូមសរសេរសេចក្តីដែលសំខាន់ជាងគេនៅក្នុង ខ ១៥-១៨ ធ្វើជាចំណុចទីមួយ : _____

_____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ៤:៤-៣០

ប្រធានបទ : ទឹករស់សំរាប់មនុស្សដែលស្រេក ។

ចំណុច :

ព្រះយេស៊ូប្រទានអោយយើងមានជីវិតដ៏បរិបូរជារៀងរហូត ។ (យ៉ូហាន ៤:៧-១៤)

ក) ហេតុអ្វីបានជាស្ត្រីសាសន៍សាម៉ារីភ្ញាក់ផ្អើល នៅពេលដែលព្រះយេស៊ូមានព្រះបន្ទូលមករកនាង ? ។_____

_____

ខ) ព្រះអម្ចាស់យេស៊ូប្រៀបប្រដូចការសង្គ្រោះទៅនឹងទឹកសំរាប់ផឹក ។ តើព្រះអម្ចាស់ប្រទានទឹកប្រភេទណាឱ្យយើង (ខ ១៣-១៤) ? ។ _____

ព្រះយេស៊ូបង្ហាញយើងថា យើងមានការខ្វះខាតខាងព្រលឹងវិញ្ញាណ ។ (យ៉ូហាន ៤:១៥-១៨)

គ) តើស្ត្រីសាសន៍សាម៉ារីមានអំពើបាបអ្វី ? ។

_____

៣- _____

ខ គម្ពីរដែលត្រូវនឹងចំណុចនេះ :_____

ខ សំខាន់ជាងគេ : _____

៤- _____

ខគម្ពីរដែលត្រូវនឹងចំណុចនេះ : _____

ខសំខាន់ជាងគេ :_____

៥- តើយ៉ូហាន ជំពូក ១១ បង្រៀនយើងអោយធ្វើកិច្ចការអ្វី ? ។

_____

_____

_____

_____

_____

_____

_____

ឃ) មនុស្សនឹងស្វែងរកការសង្គ្រោះ តែនៅពេលដែលគេយល់ច្បាស់ថា គេកំពុងបាត់បង់ក្នុងអំពើបាប ។ តើអ្នកយល់ដឹងពីគ្រោះថ្នាក់ ដែលអំពើបាបរបស់អ្នកនាំមកអោយអ្នកឬទេ ? តើអ្នកមានកែប្រែចិត្តគំនិត ហើយបែរមកសូមឱ្យព្រះជាម្ចាស់លើកលែងទោសដែរឬទេ ? ។ _____

ព្រះយេស៊ូជាសង្ឃឹមរបស់យើងអោយភ្ញាក់ឡើង ។ (យ៉ូហាន ៤:១៩-២៩)

ង) ព្រះយេស៊ូសំដែងប្រាប់ពីអង្គទ្រង់ អោយស្ត្រីសាសន៍សាម៉ារីជឿថា ព្រះអង្គជាព្រះគ្រីស្ត ។ តើជំនឿដូចនេះ មកពីណា មកពីព្រះជាម្ចាស់ ឬ ពីខ្លួនយើងផ្ទាល់ (អេភេសូ ២:៨) ? ។

_____

ច) តើយើងដឹងច្បាស់ថា ស្ត្រីសាសន៍សាម៉ារីនេះពិតជាជឿមែនដោយរបៀបណា ? ។ _____

_____

សូមធ្វើគំរោងសេចក្តីអធិប្បាយខ្លួនឯងផ្ទាល់ :

សូមធ្វើគំរោងសេចក្តីអធិប្បាយខ្លួនឯងផ្ទាល់ អំពីយ៉ូហាន ជំពូក ១១ (តាមគំរោងមុនៗ) ។ ត្រូវចែកអត្ថបទជាបី ឬ បួនផ្នែក ។ សរសេរចំណុចសំខាន់ៗជាងគេរបស់ផ្នែកនិមួយៗ :

ចំណុច :

១- _____

ខគម្ពីរដែលត្រូវនឹងចំណុចនេះ : _____

តើខណាមួយដែលសំខាន់ជាងគេ សំរាប់អោយអ្នកអានជូនក្រុមជំនុំ ? ។ _____

២- _____

ខគម្ពីរដែលត្រូវនឹងចំណុចនេះ : _____

ខសំខាន់ជាងគេ : _____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ជំពូក ១១

អានជំពូក ១១ ហើយរិះគិតពិចារណាអំពីជំពូកនេះ បន្ទាប់មក សរសេរប្រធានបទ :

ប្រធានបទ : _____

_____

តើព្រះអម្ចាស់យេស៊ូសន្យាប្រាប់នាងម៉ាថាដូចម្តេច ដើម្បីសំរាលទុក្ខនាង ? (ខ ២១-២៧) ។

_____

តើព្រះយេស៊ូបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះបុរសស្លាប់នោះ ដោយរបៀបណា ? (ខ ២៨-៣៧) ។

_____

_____

បន្ទាប់មក ព្រះយេស៊ូធ្វើអ្វី ? (ខ ៣៨-៤៤) ។

_____

_____

_____

ឆ) ព្រះជាម្ចាស់ប្រើយើងឱ្យជួយមនុស្សបាបដែលបាត់បង់ អោយជឿលើព្រះអង្គ ។ តើយើងត្រូវធ្វើដូចម្តេច ដើម្បីអាចជួយគេបាន ? ។ _____

_____

_____

_____

ចំលើយ : ក- ជនជាតិយូដា និង ជនជាតិសាម៉ារីមិនត្រូវគ្នាទេ (ព្រះយេស៊ូជាជនជាតិយូដា) ។ ខ- ទឹករស់ដែលផុសឡើងផ្តល់ជីវិតអស់កល្បជានិច្ច ។ គ- អំពើផិតក្បត់ ។ ឃ- ចំលើយផ្ទាល់ខ្លួន ។ ង- ជំនឿជាអំណោយទានរបស់ព្រះជាម្ចាស់ ។ ច- ស្ត្រីនោះនិយាយប្រាប់ពួកគេអំពីព្រះយេស៊ូគ្រីស្ត ។ ឆ- ស្រឡាញ់ពួកគេ និង ប្រាប់ពួកគេអំពីព្រះគ្រីស្ត ។

យើងស្នើសូមអោយសំដែងវគ្គនេះ ជាល្ខោននិយាយ ។ ឱ្យមនុស្សម្នាក់អានជាស្ត្រីសាសន៍សាម៉ារី ម្នាក់ទៀតជាព្រះយេស៊ូ ហើយ «អ្នកពោល » អានសេចក្តីផ្សេងៗក្នុងវគ្គ ។

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ៥:១-១៨

សូមធ្វើគំរោងអំពីយ៉ូហាន ៥:១-១៨ នេះខ្លួនឯង ។ ដំបូង សូមសិក្សាវគ្គនេះអោយបានហ្មត់ចត់សិន ។

តើវគ្គពីខ ១ ដល់ ខ ១៨ មានប្រធានបទដូចម្តេច ? ។

ប្រធានបទ :_____

_____

ចំណុច :

១- សរសេរអំពីកិច្ចការ ដែលព្រះយេស៊ូធ្វើចំពោះបុរសពិការ (ខ ១-៩) ធ្វើជាចំណុចទីមួយ :

_____

_____

២- សរសេរអំពីអ្វីៗ ដែលពួកយូដា ជាអ្នកប្រកាន់តាមក្រិត្យវិន័យ និយាយទៅកាន់បុរសពិការ (ខ ១០-១៣) ធ្វើជាចំណុចទីពីរ :

_____

_____

ការអនុវត្ត :

យើងត្រូវចេះទីពឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ។ ព្រះអង្គសន្យាថា នឹងលើកលែងទោសអំពើបាបគ្រប់យ៉ាង ដែលយើងបានប្រព្រឹត្ត និង ការពារយើងយ៉ាងរឹងមាំ ជារៀងរហូត ។



© Project WorldReach © SEAN

អ្នកគង្វាលដ៏ល្អការពារចៀមរបស់គាត់ជារៀងរហូត ដោយឫទ្ធា-
នុភាពដ៏ធំរបស់ព្រះជាម្ចាស់ ។ (យ៉ូហាន ១០:២៩-៣០)

ច) តើអ្នកណាដែលប្រទានយើងជាចៀមដល់ព្រះយេស៊ូ ? ។

_____

ឆ) តើមាននរណាម្នាក់ មានឫទ្ធានុភាពលើសពីព្រះបិតារបស់
យើង ដែលគង់នៅស្ថានបរមសុខដែរឬទេ ? ។ _____

ជ) តើយើងដឹងថា ព្រះយេស៊ូពិតជាព្រះអម្ចាស់មែន ដោយ
របៀបណា ? (ខ ៣០) ។ _____

_____

_____

ចំលើយ : ក- ចៀមទាំងនោះស្តាប់សំឡេងព្រះអង្គ និង ដើរ
តាមព្រះអង្គ ។ ខ- ពួកសិស្សដែលជឿ និង ស្តាប់បង្គាប់
ព្រះអង្គ ។ គ- ជីវិតអស់កល្ប ។ ឃ- គ្មានអ្នកណាទេ ។ ង-
ជាជីវិតអស់កល្ប ដែលនៅស្ថិតស្ថេរជារៀងរហូត ។ ច- ព្រះ
បិតា ។ ឆ- គ្មានអ្នកណាមានទេ ។ ជ- ដោយសារព្រះយេស៊ូ
និង ព្រះបិតាជាអង្គតែមួយ ។

៣- សរសេរអំពីកិច្ចការដែលបុរសពិការធ្វើ និង ពីលទ្ធផលនៃ
ការនោះ (ខ ១៤-១៨) ធ្វើជាចំណុចទីបី :

_____

_____

ការអនុវត្ត :

ពួកយូដាដែលគោរពតាមក្រិត្យវិន័យហួសហេតុ ទិតៀនព្រះយេស៊ូ
និង បុរសពិការ ដែលព្រះអង្គប្រោសអោយជា ។ តើយើងអាច
កែតម្រូវការប្រកាន់ក្រិត្យវិន័យហួសហេតុ ដែលមិនបង្ហាញសេចក្តី
មេត្តាករុណាដូចពួកយូដាទាំងនេះ នៅក្នុងក្រុមជំនុំរបស់យើង
ដោយរបៀបណា ? ។

_____

_____

_____

យើងស្នើសូមអោយសំដែងវគ្គនេះជាល្ខោននិយាយ ។ ឱ្យមនុស្ស
ម្នាក់អានជាអ្នកពោល ម្នាក់ទៀតជាព្រះអម្ចាស់យេស៊ូ ម្នាក់ទៀត
ជាបុរសពិការ និង ម្នាក់ទៀតជាជនជាតិយូដា) ។

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ៦:១-១៥

សរសេរប្រធានបទរបស់វគ្គទាំងមូល :

ប្រធានបទ : _____

_____

ដំបូង អ្នកអាចប្រាប់សាច់រឿងទាំងមូល ហើយបន្ទាប់មក ពន្យល់ចំណុចខាងក្រោមនេះ :

ព្រះយេស៊ូបង្កើនចំនួនរបស់អ្វីៗ ដែលយើងថ្វាយទៅព្រះអង្គ ។

សូមកត់សំគាល់ថាព្រះអម្ចាស់បាននំប៉័ង និង ត្រីមកពីណា (ខ ៨-៩) ។ ក្មេងប្រុសម្នាក់ថ្វាយរបស់បន្តិចបន្តួច ដែលវាមាន ទៅព្រះយេស៊ូ) ។ តើយើងអាចធ្វើដូចម្តេច ដើម្បីធ្វើតាមគំរូក្មេងប្រុសនោះ ? ។

_____

_____

_____

_____

_____

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ជំពូក ១០

ប្រធានបទ : ការងាររបស់អ្នកគង្វាលដ៏ល្អ (ខ ២៧-៣០) ។

ចំណុច :

អ្នកគង្វាលដ៏ល្អថែរក្សាហ្វូងចៀមរបស់គាត់ ។ (យ៉ូហាន ១០: ២៧)

ក) តើចៀមរបស់ព្រះយេស៊ូ ធ្វើអ្វី ? ។

_____

ខ) តើអ្នកណាជាចៀមរបស់ព្រះយេស៊ូគ្រីស្ត ? ។_____

អ្នកគង្វាលដ៏ល្អការពារចៀមរបស់ខ្លួនជារៀងរហូត ។ (យ៉ូហាន ១០:២៨)

គ) តើព្រះយេស៊ូប្រទានអ្វីដល់ពួកអ្នកដែលជារបស់ព្រះអង្គ ? ។

_____

ឃ) តើមានអ្នកណាអាចលួចយកពួកគេបានទេ ? ។ _____

ង) តើជីវិតក្នុងព្រះគ្រីស្តមានរយៈពេលប៉ុន្មាន ? ។_____

_____

© Project WorldReach © SEAN

ការអនុវត្ត :

តើព្រះយេស៊ូប្រោសអ្នកជឿគ្រប់រូប កុំឱ្យខ្វាក់ខាងព្រលឹងវិញ្ញាណ ដោយរបៀបណា ? ។ _____

_____

ក្រោយពេលដែលព្រះអម្ចាស់ប្រោសយើង អោយភ្លឺខាងព្រលឹងវិញ្ញាណហើយ តើយើងអាចមានទុក្ខលំបាកអ្វីខ្លះ ? ។

_____

_____

ហេតុអ្វីបានជាពួកអ្នក ដែលមិនទូលសូមអោយព្រះយេស៊ូសង្គ្រោះពួកគេ នៅតែខ្វាក់រហូត ? ។_____

_____

_____

យើងស្នើសូមអោយអានរឿងនេះ តាមរបៀបល្ខោននិយាយ ។ សូមអោយម្នាក់អានជាសាវ័កម្នាក់ ម្នាក់ទៀតជាព្រះយេស៊ូ ម្នាក់ទៀតជាមនុស្សខ្វាក់ ម្នាក់ទៀតជាជនជាតិយូដា ម្នាក់ទៀតជាឪពុកម្តាយ និង ម្នាក់ទៀតជាអ្នកពោល ។

_____

ព្រះជាម្ចាស់នឹងធ្វើអោយអ្វីៗ ដែលយើងថ្វាយទៅព្រះអង្គ ដោយធ្វើពលិកម្ម និង ដោយសេចក្តីស្រឡាញ់ ក្លាយជាព្រះពរ ។

សរសេរអំពីព្រះអង្គយកចំណីអាហាររបស់ក្មេងប្រុស ទៅធ្វើអ្វី ? ។

_____

បើសិនជាយើងថ្វាយដង្វាយដោយជំនឿ តើព្រះអម្ចាស់អាចយកដង្វាយរបស់យើងទៅធ្វើអ្វីខ្លះ ? ។

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

© Project WorldReach © SEAN

គំរោងសេចក្តីអធិប្បាយអំពី យ៉ូហាន ជំពូក ៩

ប្រធានបទ : ភាពខ្វាក់ខាងព្រលឹងវិញ្ញាណ ។

ជួនកាល យើងអធិប្បាយវគ្គមួយវែង ។ សូមកុំអានវគ្គនោះទាំងមូល ខ្លាចក្រែងក្រុមជំនុំធុញ ។ ដំបូង ត្រូវសិក្សាសាច់រឿងនេះសិន ដោយអានតែខសំខាន់ៗបានហើយ រួចសង្ខេបសេចក្តីផ្សេងៗទៀតក្នុងវគ្គ ។ ដើម្បីនិយាយពីមនុស្សពិការភ្នែកនៅក្នុង យ៉ូហាន ជំពូក ៩ សូមចែកវគ្គនេះជាបីចំណុច ។

ចំណុច :

ព្រះយេស៊ូគ្រីស្តធ្វើឱ្យភ្នែកខាងព្រលឹងវិញ្ញាណរបស់យើងភ្លឺឡើង ។ (យ៉ូហាន ៩:១-១២)

នៅពេលដែលយើងអធិប្បាយ សូមអានតែ ខ ១-៣ ហើយសង្ខេបរឿងរហូតដល់ ខ ១២ ។

បើមានភ្នែកភ្លឺ គឺមានការទទួលខុសត្រូវ ។ (យ៉ូហាន ៩:១៣-៣៤)

អាន ខ ១៣-១៥ ហើយសង្ខេបរឿងរហូតដល់ ខ ៣៤ ។

ពួកអ្នកដែលមើលឃើញ តែដោយភ្នែករបស់រូបកាយ នឹងនៅតែខ្វាក់ដដែល ។ (យ៉ូហាន ៩:៣៥-៤១)

(អាន ខ ៣៥-៣៩ ហើយសង្ខេបរឿងរហូតដល់ ខ ៤១) ។

© Project WorldReach © SEAN